# ខ្លឹមសារនៃអាហារូបករណ៍វិទ្យាល័យ ខេត្តកាណាហ្គាវ៉ា

## 1 គោលដៅប្រាក់កម្ចី

អ្នកដែលមានស្ថានភាពដូចទៅនឹងア ឬ イ

ア សិស្សដែលរស់នៅក្នុងខេត្តនិងបានចុះឈ្មោះចូលរៀននៅវិទ្យាល័យក្នុងខេត្ត។ល។សិស្សកំពុងរៀន(វិទ្យាល័យ ,មធ្យមសិក្សាវគ្គបញ្ចប់និងវិទ្យាល័យពិសេស(សម្រាប់សិស្សខ្សោយសតិ)ដែលត្រូវការជំនួយជាដើម។

イ សិស្សដែលមានឪពុកម្តាយរស់នៅក្នុងខេត្ត ហើយកំពុងរៀននៅវិទ្យាល័យឬសាលាវិជ្ជាជីវៈជាដើម។

## 2 ព័ត៌មានលម្អិតអំពីប្រាក់កម្ចី

| | |
|---|---|
| **(1) ប្រាក់កម្ចីប្រចាំខែ (សិស្សចូលថ្មី)** | សាលារដ្ឋ**¥10,000 , ¥20,000 ឬ ¥30,000** (សូមជ្រើសរើសយក1)<br>សាលាឯកជន៖ **¥10,000 ,￥20,000 ,￥30,000 ,￥40,000 ឬ ¥50,000** (សូមជ្រើសរើសយក1)<br>*សម្រាប់សិស្សឆ្នាំទី2ឡើងទៅនិងត្រូវបានកាត់បន្ថយ¥10,000ប៉ុន្តែនៅពេលដាក់ពាក្យ(មានលក្ខខណ្ឌ)អ្នកក៏អាចទទួលបានបន្ថែម¥10,000គឺអាចទទួលបានចំនួនប្រាក់កម្ចីដូចគ្នាទៅនឹងសិស្សចូលថ្មីដែរ។ |
| **(2) រយៈពេលកម្ចី** | ចំនួនមួយឆ្នាំចាប់ពីខែមេសាដល់ខែមីនានៃឆ្នាំបន្ទាប់ (ក្នុងករណីជ្រើសរើសបម្រុង/ជ្រើសរើសតាមកាលកំណត់) |
| **(3) យន្តការនៃប្រាក់កម្ចី** | ប្រាក់នឹងត្រូវបានផ្ទេរទៅគណនីធនាគារដែលម្ចាស់ខ្លួន3ដងក្នុងមួយឆ្នាំ។ចុងខែកក្កដា(ប្រាក់សម្រាប់ខែមេសា ដល់ខែកញ្ញា) ចុងខែតុលា (ប្រាក់សម្រាប់ខែតុលា ដល់ខែធ្នូ) និងចុងខែមករា (ប្រាក់សម្រាប់ខែមករា ដល់ខែមីនា)។ (ឧទាហរណ៍នៃការជ្រើសរើសតាមកាលកំណត់) |

## 3 អ្នកធានារ៉ាប់រង

**ជាគោលការណ៍តម្រូវអោយមានអ្នកធានាពីរនាក់*។**

*ឪពុកឬម្តាយម្នាក់និងមនុស្សពេញវ័យម្នាក់ដែលរកចំណូលបានដោយឯករាជ្យ។ បន្ទាប់ពីប្រាក់កម្ចីត្រូវបានសម្រេចចិត្ត អ្នកនឹងត្រូវដាក់លិខិតបញ្ជាក់ការចុះបញ្ជីត្រានៅសាលាសង្កាត់។

## 4 របៀបដាក់ពាក្យ

### ① ការជ្រើសរើសបំរុង(ត្រូវដាក់ពាក្យមុនចូលវិទ្យាល័យ )

| | |
|---|---|
| **(1) ដំណឹងជ្រើសរើសជាដើម** | ព័ត៌មានលម្អិតនៃការជ្រើសរើស,កំឡុងពេលនៃការដាក់ពាក្យ,ទម្រង់ដាក់ពាក្យជាដើម**ត្រូវបានប្រកាសតាមរយៈអនុវិទ្យាល័យ**នៅអំឡុងខែវិច្ឆិកា។ដូច្នេះសូមទាក់ទងគ្រូប្រចាំថ្នាក់។(ក៏មានបង្ហោះនៅលើគេហទំព័ររបស់ខេត្តផងដែរ) |
| **(2) ទីកន្លែងដាក់ពាក្យ** | ដាក់ពាក្យទៅក្រុម**ប្រឹក្សាអប់រំខេត្តកាណាហ្គាវ៉ា ផ្នែកហិរញ្ញវត្ថុ**។<br>បន្ទាប់ពីពិនិត្យឯកសាររួចការសម្រេចនឹងត្រូវបានធ្វើឡើងមុនពេលចូលរៀន។ប៉ុន្តែបន្ទាប់ពីចូលរៀននៅវិទ្យាល័យជាដើម សិស្សនឹងត្រូវដាក់ពាក្យស្នើម្តងទៀតទៅកាន់វិទ្យាល័យដែលពួកគេបានចូល។ |
| **(3) អាហារូបករណ៍បណ្តោះអាសន្នរយៈពេលខ្លី** | អ្នកដែលត្រូវបានជ្រើសរើសបម្រុងហើយដែល**មានបំណងចង់ទទួលអាហារូបករណ៍បណ្តោះអាសន្នរយៈពេលខ្លី នឹងអាចទទួលប្រាក់មួយចំនួននៃអាហារូបករណ៍នៅក្នុងខែមីនា មុនពេលចូលវិទ្យាល័យ។** |

### ② ការជ្រើសរើសតាមកាលកំណត់(ដាក់ស្នើបន្ទាប់ពីចូលវិទ្យាល័យ )

| | |
|---|---|
| **(1) ដំណឹងជ្រើសរើស** | ព័ត៌មានជ្រើសរើសនិងលិខិតដាក់ពាក្យនឹងត្រូវបាន**ចែកចាយនៅតាមវិទ្យាល័យ** (ក៏មានចុះនៅលើគេហទំព័ររបស់ខេត្តផងដែរ)<br>សម្រាប់នីតិវិធីនៃការដាក់ពាក្យ សូមទាក់ទងទៅអ្នកទទួលខុសត្រូវនៅវិទ្យាល័យនីមួយៗ។ |
| **(2) កន្លែងដាក់ពាក្យ** | ត្រូវការការបញ្ជាក់ពីនាយកសាលា ដូច្នេះ**សូមដាក់ពាក្យតាមរយៈវិទ្យាល័យរបស់អ្នក**។ |
| **(3) រយៈពេលនៃការដាក់ពាក្យ** | ការជ្រើសរើសតាមកាលកំណត់នឹង**ចាប់ផ្តើមនៅខែមេសា**។ សូមដាក់ពាក្យតាមកាលកំណត់ដែលកំណត់ដោយវិទ្យាល័យនីមួយៗ។<br>*ប្រសិនបើអ្នកត្រូវការប្រាក់កម្ចីបន្ទាប់ពីថ្ងៃផុតកំណត់អ្នកក៏អាចនៅដាក់ពាក្យសុំបាន។ (អាចដាក់ពាក្យរហូតដល់ចុងខែមករា) |

## 5 វិធីសាស្ត្រសងប្រាក់

| | |
|---|---|
| **(1) រយៈពេលសងប្រាក់ជាដើម** | ប្រាក់កម្ចីត្រូវសងវិញក្នុងរយៈពេលយូជាង4ដងនៃរយៈពេលកម្ចីដោយចាប់ផ្តើម 6 ខែបន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ។ ការសងប្រាក់អាចសងជាខែ (រៀងរាល់ខែ) សងផ្តាច់សរុបកន្លះឆ្នាំ (សងក្នុងខែកក្កដានិងធ្នូជារៀងរាល់ឆ្នាំ)ឬមួយឆ្នាំម្តង(សងក្នុងខែធ្នូជារៀងរាល់ឆ្នាំ)។អាហារូបករណ៍ថ្នាក់វិទ្យាល័យគឺមិនយកការប្រាក់ទេ។ |
| **(2) រយៈពេលអនុគ្រោះសម្រាប់ការសងប្រាក់។** | ប្រសិនបើអ្នកបន្តទៅសកលវិទ្យាល័យជាដើមអ្នកអាចនឹង**អាចដាក់ពាក្យសុំពន្យាពេលនៃការសងប្រាក់។ លើសពីនេះការសងប្រាក់អាចត្រូវបានលើកលែងក្នុងករណីត្រូវនឹងលក្ខខណ្ឌ។** |

## 6 ព័ត៌មានសម្រាប់ទំនាក់ទំនង

ក្រុមប្រឹក្សាភិបាលនៃខេត្តកាណាហ្គាវ៉ា ផ្នែកហិរញ្ញវត្ថុ ក្រុមអាហារូបករណ៍វិទ្យាល័យ ទូរស័ព្ទ(045)210-8251(ខ្សែផ្ទាល់)

គេហទំព័រ http://www.pref.kanagawa.jp/docs/en7/cnt/f324/